ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ១៥៣៨ ព.ណ.ឱកល.

ថ្ងៃសុក្រ ១០ រោច ខែចេត្រ ឆ្នាំថោះ ឆស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែឧសភា ឆ្នាំ ២០២៤

# សេចក្ដីជូនដំណឹង
## ស្ដីពី
## យន្តការលើកទឹកចិត្តនានា សម្រាប់ការចុះបញ្ជីពាណិជ្ជកម្មដោយស្ម័គ្រចិត្ត របស់វិស័យព័ត៌មាន និងសោតទស្សន៍

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូន លោក-លោកស្រី ដែលកំពុងប្រកបអាជីវកម្មក្នុងវិស័យព័ត៌មាន និងសោតទស្សន៍ មេត្តាជ្រាបថា យោងតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងកម្មវិធីសំណេះសំណាល និងពិសារអាហារសាមគ្គីជាមួយអ្នកសារព័ត៌មានលើកទី៦ នាថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៤ ក្រសួងពាណិជ្ជកម្ម បានសម្រេចផ្ដល់ការលើកទឹកចិត្តទៅដល់លោក-លោកស្រី ដែលមានបំណងចុះបញ្ជីពាណិជ្ជកម្មក្នុងវិស័យព័ត៌មាន និងសោតទស្សន៍ដូចតទៅ៖

១. ការលើកលែងកាតព្វកិច្ចបង់កម្រៃសេវាសាធារណៈចុះបញ្ជីពាណិជ្ជកម្មរយៈពេល ៣ឆ្នាំ និង

២. ការលើកលែងការផាកពិន័យនានា សម្រាប់អាជីវកម្មដែលបានដំណើរការ និងមិនបានចុះបញ្ជីត្រឹមត្រូវ

សេចក្ដីដូចបានជម្រាបជូនខាងលើ ក្រសួងពាណិជ្ជកម្ម មានជំនឿយ៉ាងមុតមាំថា លោក-លោកស្រី ដែលប្រកបអាជីវកម្មក្នុងវិស័យព័ត៌មាន និងសោតទស្សន៍នឹងចូលរួមដោយស្ម័គ្រចិត្តក្នុងការចុះបញ្ជីយ៉ាងផុសផុលជាមិនខាន។

សម្រាប់ព័ត៌មានលម្អិតសម្រាប់ការដាក់ពាក្យស្នើសុំតាមរយៈប្រព័ន្ធស្វ័យប្រវត្តកម្មនេះ លោក-លោកស្រី អាចចូលទៅកាន់គេហទំព័រ www.registrationservices.gov.kh (ដូចមានជូនភ្ជាប់ QR កូដខាងក្រោម) ឬ អាចធ្វើការទំនាក់ទំនងផ្ទាល់ទៅកាន់លេខ ១២៦៦ ៕

| | |
|---|---|
| លេខទូរស័ព្ទ | ១២៦៦ |
| គេហទំព័រ | www.registrationservices.gov.kh |

សូមអរគុណ!

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម